# ប្រវត្តសាស្ត្រ នៅស្រុកខ្មែរ

## Les Histoires au Cambodge

**សរសេរដោយ ឧប សៅ-សង្ហា**

**ថ្ងៃទី ២៨ តុលា ឆ្នាំ ២០១៤**



# មាតិការឿង


**សេចក្តីផ្តើម**

**បទដ្ឋានប្រវត្តិសាស្រ្ត នៅស្រុកខ្មែរ**

១- ប្រវត្តិសាស្រ្ត ជាវិទ្យាសាស្រ្ត

២- ប្រវត្តិសាស្រ្ត ផ្នែកសាមញ្ញ

- អំពីបញ្ហា ការចុះកាលបរិច្ឆេទ

៣- ប្រវត្តិសាស្រ្ត ថ្មី

**សេចក្តីសន្និដ្ឋាន**

# សេចក្តីផ្តើម

ប្រវត្តិសាស្ត្រ តែងតែទាក់ទាញអារម្មណ៍មនុស្ស ឲចង់ដឹងឮជានិច្ច ព្រោះវា ជា សតិរបស់មនុស្សលោក[1] ដែល ប្រវត្តិសាស្ត្រវិទូ, អ្នកស្រឡាញ់វក់ (dilettantes) ប្រវត្តិសាស្ត្រ, អ្នកផ្សាយចំណេះថ្មីបែបសាមញ្ញ (vulgarisateurs) យកមកផ្សាយ តាមវាចាក្តី តាមការសេសេរក្តី សំរាប់ជាចំណេះ[2] ដល់សាធារណជន។ បើសិនជា ចំណេះចេះដឹង នេះ វាមានជោគជ័យ ក្នុងចិត្ត មហាជន គឺ ពិត ជា វា មាន សារប្រយោជន៍ ដ្បិត វា នាំឲ មហាជន ចូលរួម ចិញ្ចឹម **សតិសមូហជន**[3]។

តែប្រវត្តិសាស្ត្រវិទូ យល់ឃើញថា ចិញ្ចឹម សតិសមូហជន ត្រូវចាំបាច់ អ្នកផ្សាយចំណេះមានចំណូលចិត្ត, មាន រចនាបថ (style), មាន ការរំជើបរំជួលចិត្តក៏ដូចគ្នា នឹងត្រូវមាន **ឧកដ្ឋភាព** (ការហ្មត់ចត់) និង គោលវិធី នោះដែរ។ ចំពោះ ប្រវត្តិសាស្ត្រវិទូ វិទ្យាសាស្ត្រ នេះឯង ជាការធានានៃតម្លៃ នូវចំណេះវិទ្យា នៃប្រវត្តិសាស្ត្រ។ តែក្នុងនាមវិទ្យាសាស្ត្រ បើប្រវត្តិសាស្ត្រវិទូ ទុកចំណេះប្រវត្តិសាស្ត្រ គ្រាន់ជា **ពាហុសុតភាព** (érudition) ផ្អែកទៅលើតែឯកសារ មានចំនួនតិចតួចតែប៉ុណ្ណោះ ដោយមិនប្រើ មនោគតិ (imagination) តាមផ្លូវបញ្ញា គឺច្បាស់ជាប្រវត្តិសាស្ត្រ បែបនេះ នៅ ជា ចំណេះ ឋិតិវន្ត (statique) សំរាប់តែកត់ទុក បន្ថែមជាឯកសារ តែវាគ្មានសារប្រយោជន៍ច្រើន ដល់មហាជន ដែលជាអ្នកអានប្រកបទៅដោយ មនោគតិ ដើម្បីឲមានជារូបភាព រស់រវើកក្នុងអារម្មណ៍របស់ខ្លួន។ ប្រវត្តិសាស្ត្រ ដែលជា សារាណីយ (mémorable) ចំពោះមហាជន គឺជា ប្រវត្តិសាស្ត្រ ទាក់ទាញ **ញាណិច្ចតា** (ការចង់ដឹងចង់ឃើញ, curiosité) របស់មហាជន ដូច្នេះ គុណសម្បត្តិរបស់ ប្រវត្តិសាស្ត្រវិទូ មិនត្រូវ មាន ត្រឹមតែ ជាអ្នកវិទ្យាសាស្ត្រ ត្រូវមានបន្ថែម ជា សិល្បករ-ផលិករ ប្រវត្តិសាស្ត្រ ព្រោះប្រវត្តិសាស្ត្រ ជា វិជ្ជាផង ជា វិចិត្រសិល្បៈ ផងដែរ។ រួមសេចក្តីមកប្រវត្តិសាស្ត្រ គេអាចទុក ជា សម្ពន្ធចំណេះ រវាង ពាហុសុតភាព និង ចំណេះកើតចេញពី មនោគតិ របស់ប្រវត្តិវិទូ មានគុណសម្បត្តិ ជា អ្នកស្រាវជ្រាវ ប្រវត្តិសាស្ត្រ តាមឯកសារ និង ជា មនុស្ស មាន មនោគតិ[4]។ តែ ប្រវត្តិសាស្ត្រ ជាចំណេះ ដោយមផ្សត តែ ក៏ជា រឿងសំរាប់អានកំសាន្ត និង សំរាប់ ការចង់ដឹង នោះដែរ។

សួរថា តើខ្មែរយើង ចូលចិត្តអាន ប្រវត្តិសាស្ត្រជាតិខ្លួនដែរឬទេ ? សព លោក កេង-វាន់សាក់ អ្នកប្រាជ្ញ អក្សរសាស្ត្រខ្មែរ មួយរូប មាន មតិថា ជាតិសាសន៍ខ្មែរ មាន វប្បធម៌ ជា វាចា ច្រើនជាង វប្បធម៌ ជាអក្សរ។ ការជ្រួតជ្រាបបែបនេះ នាំឲខ្មែរយើង មិនសូវចូលចិត្តអាន

[1] សតិរបស់មនុស្ស=Mémoire d’hommes។
[2] ចំណេះ=Connaissances។
[3] សតិសមូហជន=Mémoire collective។
[4] L’homme d’archives et l’homme d’imagination។

ហើយ មិនចូលចិត្ត សរសេរ សៀវភៅ។ ក្នុងការអប់រំសោធ ខ្មែរអាចរៀនសូត្រ ឲចេះចាំ មិនចាំបាច់រៀនអក្សរ ឲចេះអាន។ បើជនណា ចេះសូត្រ ឡើងវិញ នូវចំណេះអ្វីមួយ គេតែងទុកជននោះជាអ្នកប្រាជ្ញ។ ហេតុនេះឯង ពាក្យ អ្នកប្រាជ្ញ មានន័យ ពីរយ៉ាង គឺ អ្នកចេះសូត្រ តាមគ្រូផង និង អ្នកគោរពគ្រូផង។ ពាក្យ ចេះ ក្នុងន័យបែបនេះ ជា «**ចំណេះចម្លង**» ឬ ចំណេះគ្មាន**បញ្ញា** (ចេះដឹងច្បាស់ នូវសេចក្តីពិត)។ ឧទាហរណ៍៖ ខ្មែរយើងភាគច្រើន នាំគ្នា រៀនសូត្រធម៌ព្រះពុទ្ធ ជាភាសាបាលី ចេះចាំមាត់ តែជួនកាល ឥតយល់ន័យអ្វីបន្តិចសោះឡើយ។

ទស្សនៈ លោក កេង-វាន់សាក់ ស្តីអំពី ***វប្បធម៌វាចា*** មាននៅក្នុងសង្គមខ្មែរ មិនអាចបញ្ជាក់បាន ថាខ្មែរ មិនចូលចិត្ត អាន និង សរសេរសៀវភៅ នោះទេ ព្រោះនៅស្រុកខ្មែរ មានចំនួន សៀវភៅ ជាភាសាជាតិ តិចតួចបំផុត មិនអាច ទាក់ទាញ មហាជន ឲចូលចិត្តអានសៀវភៅ នោះឡើយ។ ចំណែក ការសរសេរវិញ ស្រុកខ្មែរ នៅខ្វះរោងពុម្ព បោះពុម្ពសៀវភៅ ដើម្បីលើកទឹកចិត្ត ខ្មែរឲសរសេរសៀវភៅ ផ្សាយគំនិត តាមការសាកល្បងសិក្សា ឬ មនោសញ្ចេញនាតាមប្រឡោមលោក។ នៅស្រុកខ្មែរ អ្នកចេះភាសាបរទេស មានការពិបាក រកសៀវភៅ បរទេសអាន ណាស់ ព្រោះ តម្លៃសៀវភៅ មានកំរិតខ្ពស់ណាស់ លើសពីសមត្ថភាព ហេរញ្ញវត្ថុ ខ្លួន។ បើនិយាយ អំពី ចំនួន បណ្ណាគារ និង បណ្ណល័យ វិញ គឺ នៅមានតិចតួចបំផុត នៅក្នុងប្រទេស។ ***វប្បធម៌អក្សរ*** កើតមានឡើងបាន ពីនយោបាយ អប់រំមហាជន របស់ អ្នកដឹកនាំជាតិ តែបើពួកអស់លោក ទាំងនោះ គាត់គ្មាន មហិច្ឆិតា ចង់ឲជាតិរុងរឿង នោះទេ ច្បាស់ជា ជនខ្មែរ ម្នាក់ៗ នាបច្ចុប្បន្នកាលនេះ នាំគ្នាយកភាសាឃួនក្តី អង់គ្លេសក្តី ជាភាសាសិក្សា ព្រោះវា ជា ភាសាមានប្រយោជន៏ ដល់ការរស់នៅ របស់ខ្លួន។ ភាសាខ្មែរនៅក្នុងអនាគតកាល នឹងក្លាយជាគ្រាមភាសា របស់ជនជាតិ ភាគតិចមួយ នៅស្រុខ្មែរ ឬ ជា ភាសា របស់ អ្នក ដែលមិនបានរៀននៅក្នុងសាលា ដែលមាន ភាសា បរទេសជាមូលដ្ឋាន។

លោក វ៉ាន់-ឌីអុន បានសរសេរក្នុងសៀវភៅ ប្រវត្តិសាស្ត្រខ្មែរ របស់លោកមួយ មានចំណងជើងថា «**សុបិន និងការពិត**» ថា៖ ខេមរៈយានកម្ម ក្នុង កម្មវិធីសិក្សា នៅក្នុង ទស្សវត្សរ៍ ១៩៦៥ នាំឲមានការចុះអន់ថយខ្លាំង នូវកំពស់ចំណេះវិជ្ជា យុវជនខ្មែរ ព្រោះខ្មែរយើង នៅខ្វះសៀវភៅគ្រប់មុខវិជ្ជា ជាភាសាជាតិ សំរាប់ សិស្សានុសិស្ស ទុកជាឯកសារសិក្សា។

ទស្សនៈបែបនេះ យើងមិនអាច យល់ស្របតាម បាននោះឡើយ ព្រោះការទុកភាសាបារាំង ជាភាសាសិក្សា សំរាប់យុវជនខ្មែរ ជាចំណោទមួយសំខាន់ណាស់ ដល់នយោបាយអប់រំជាតិ ដល់មហាជន (éducation de masse)។ ទាំងគ្រូ ទាំងសិស្ស ឥតអាចចេះស្ទាត់ ភាសាបារាំង នាំគ្នាបង្កើត **ភាសា កូនកាត់** ដូចយ៉ាង គ្រូពន្យល់សិស្ស ជាភាសាខ្មែរ ឯចំណែកសិស្ស យកមេរៀន ជាភាសាបារាំង ទៅរៀនសូត្រ ឲចាំមាត់ ហើយបើ នរណាម្នាក់ មានសតិធំ អាចចាំបានច្រើន ជាងអ្នកដែលមានសតិតូច គឺគេទុកក្មេងនេះ ជាមនុស្សមានប្រាជ្ញា។ សិក្សាបែបនេះ មិនមែនជាគោលវិធី សំរាប់អប់រំបញ្ញា ឲរីកចំរើន បានច្រើននោះឡើយ។ ពិតប្រាកដ ណាស់ ថាមានអ្នកមានសតិធំ អាចចេះចាំបានច្រើន តែចំនួន ជនទាំងនោះ មានអត្រាទាបណាស់ ក្នុងចំណោមសិស្សនុសិស្ស មាននៅក្នុងប្រទេស។ រីឯ បញ្ហា កង្វះ សៀវភៅ និង ឯកសារ ជាភាសាជាតិ ជាការ

លើក បញ្ហាមកចោទ មិនសមហេតុ ព្រោះ វាជាបញ្ហា មធ្យោបាយ និង ឆន្ទៈ នយោបាយ តែប៉ុណ្ណោះ។ អប់រំ ដល់មហាជន មិនមែន នៅត្រឹមតែ ជា ការសិក្សា ភាសា បរទេស ឲចេះសិន សំរាប់ យកវាទៅរៀន ចំណេះវិជ្ជា ផ្សេងៗទៀត នោះឡើយ។ អប់រំជាតិ គឺ បង្រៀន និង ពន្យល់ យុវជន ឲយល់ដឹង ពិត និង ច្បាស់លាស់អំពី គ្រឹះរបស់ជាតិ ដែលមាន ភាសាជាតិ ទុកជាសសរគោល នៃវប្បធម៌ជាតិ។ តែក៏ត្រូវ លើកទឹកចិត្ត យុវជនខ្មែរ ឲខំរៀនភាសាបរទេសដែរ ព្រោះជាមធ្យោបាយ សំរាប់បើក គតិ (esprit) កូនខ្មែរ ឲបាន ទូលំទូលាយ ដើម្បី ឲមាន ការប្រទាក់គ្នា (connexion) ជាមួយ នឹង សភាពចំរើន មាននៅក្នុងពិភពលោកបច្ចុប្បន្ន ដែលជា ផ្កាយព្រះគ្រោះ មាន មនុស្សលោក រស់នៅ លើដីនេះ ស្ទើរ តែ លែង មាន ព្រំដែនរដ្ឋ ក្នុងវិស័យ ចំណេះចេះដឹង សំរាប់ មនុស្សលោក ទៅហើយ។ ការសង្កេត ៖ នៅក្នុង បណ្ដាប្រទេស អាហ្វ្រិក (Afrique) ដែលគ្មានភាសាជាតិ នៅតែបន្តយកភាសា ពួកអ្នកអាណានិគម ជាភាសាសិក្សា ក៏មិនឃើញមានការរីកចំរើនលើសលុបនោះដែរ។ យើងអាចសន្និដ្ឋានបាន ថា **ខេមរៈយានកម្ម** មិនមែនជាចំណោទ ដល់អភិវឌ្ឍន៍ជាតិនោះឡើយ។ ផ្ទុយទៅវិញ វាជា ការកែ គំនិតខ្មែរ ឲបែរមករកមូលដ្ឋានដើមខ្មែរ ក្នុងវិស័យ វប្បធម៌ជាតិ ដែលខ្មែរយើង ធ្លាប់មាន ច្រើនសតវត្សមកហើយ។ ត្រូវដឹងថា ខ្មែរដែលចេះភាសាបរទេស ត្រឹមតែមួយចំនួនតូច មិនគួរ វាយ តម្លៃ ភាសាបរទេស ថាជា តម្លៃជាតិខ្មែរ នោះទេ។

ត្រឡប់មក រកសំនួរ សួរថា តើខ្មែរយើង ចូលចិត្ត ចង់ចេះ ដឹងអំពីប្រវត្តិសាស្ត្រជាតិខ្លួនឯងដែរឬទេ ?

ចូលចិត្ត ចង់ចេះដឹង លុះត្រា តែមានអ្នកនិយាយប្រាប់ ប្រកប ដោយ វោហារកោសល្យ, មានសៀវភៅ សំរាប់អាន ដែលមាន អន្តរវត្ត[5] អាចនាំ ឲមាន ញាណិច្ឆតា។ តែបើប្រវត្តិសាស្ត្រ សំរាប់តែសរសើរ បុគ្គល ឬ ជាជំនឿឥតសមហេតុ នាំឲ អ្នកស្ដាប់ ឬ អ្នកអាន មានការធុញថប់ក្នុងចិត្ត ដូចគ្នា នឹង អ្នក ចង់ស្ដាប់ ចម្រៀង តែ អ្នកច្រៀង គាត់ច្រៀង មិនពិរោះនុះដែរ។ ហេតុនេះឯង អន្តរវត្ត នៃ ប្រវត្តិសាស្ត្រ ដើម្បីទាក់ទាញចិត្ត មហាជន ឲចង់ដឹង មិនត្រឹមតែ ត្រូវមានការពិត និង គុណសម្បត្តិ របស់វា ប៉ុណ្ណោះទេ គឺ អ្នកសរសេរក្ដី អ្នកនិយាយរឿងក្ដី ត្រូវមានគរុកោសល្យ សំរាប់ផ្សាយ គំនិតខ្លួនផងដែរ ព្រោះ សង្គមមនុស្ស ជា សង្គមនិយម សោភ័ណភាព ជារូបភាពក្ដី ជា អរូបភាពក្ដី។

មាន ស្នាដៃ និពន្ធប្រវត្តិសាស្ត្រ ពីរផ្នែកៈ ស្នាដៃនិពន្ធ អ្នកប្រវត្តិសាស្ត្រវិទូ ឬ អ្នក ឯកទេសមនុស្សសាស្ត្រ និង ស្នាដៃនិពន្ធ តាមរបៀប **ប្រជាធិបតេយ្យនិយកម្ម**។ ក្នុងផ្នែកទី២ នេះឯងដែលមាន **ឥតរវជន** (profane) ជាអ្នកស្រឡាញ់ ប្រវត្តិសាស្ត្រ យក ព្រឹត្តិការណ៍ ជាប្រវត្តិសាស្ត្រមកនិពន្ធ ជាការសាកល្បងក្ដី ជាប្រឡោមលោកក្ដី សំរាប់ទុកជូនមហាជន យកមកអានកំសាន្ត។ ឧទាហរណ៍ ដូចជា សពលោក បីរ-ឆៃលាង លោកបាន និពន្ធ ប្រលោមលោក ដ៏ល្បីមួយគឺ រឿង « **ព្រះចន្ទរាជា**» ដែលទាញចិត្តខ្មែរ ជាពិសេសក្នុងចំណោមយុវជន ឲចង់អាន ព្រោះលោក ជាអ្នក

[5] អន្តរវត្ត=Continu។

និពន្ធ ទេពនិមិត។ ស្នាដៃនេះ មានសារប្រយោជន៍ ណាស់ ព្រោះ ដូចបាន ជំរាប ខាងលើរួចមក ហើយ ថា វា នាំមហាជន ឲ ចូលរួមចិញ្ចឹម សតិសម្ូហជន។

# បទដ្ឋាន[6] ប្រវត្តិសាស្ត្រ នៅស្រុកខ្មែរ

## ១. ប្រវត្តិសាស្ត្រវិទ្យា

នៅស្រុកខ្មែរ ប្រវត្តិសាស្ត្រខ្មែរ សរសេរដោយ ប្រវត្តិសាស្ត្រវិទូ ជាចំណេរ ក្នុងភាសាបរទេស ជាប្រវត្តិសាស្ត្រ មានលក្ខណៈជាវិជ្ជាវិទ្យាសាស្ត្រ សំរាប់អ្នកឯកទេសមនុស្សសាស្ត្រ ឬ និស្សិត្រនៃប្រវត្តិសាស្ត្រវិទ្យា ទុកជាឯកសារ សំរាប់ សិក្សា ឬ ធ្វើការស្រាវជ្រាវ បន្ត រកការពិត សំរាប់ការចេះដឹង នៃមនុស្សជាតិ។ ចំណេះប្រវត្តិសាស្ត្រខ្មែរ មានបទដ្ឋានសំខាន់ ជាចំណេះ ផ្នែក បុរាណវត្ថុវិទ្យា សិក្សាអំពី ប្រាសាទសិលាបុរាណខ្មែរ មានចំនួនច្រើនរាប់ពាន់ ប្រកបដោយក្បាច់រចនា គួឲកោតស្ញប់ស្ញែង ជាពិសេស បរិក្ខារសង្ហេរណ្ឌ (បារាយ ទំនប់ទឹក) សំរាប់ទ្រទ្រង់ សេដ្ឋកិច្ច បូរី។ ដោយសារ ចំណេះវិទ្យាសាស្ត្រនេះ អ្នកប្រាជ្ញបារាំង គេអាចយកធ្វើកញ្ចក់ ឆ្លុះរកឃើញ ប្រវត្តិសាស្ត្រខ្មែរ ជាក់ច្បាស់ នូវសម័យមុនអង្គរ និង សម័យអង្គរ ហើយគេទុក សម័យអង្គរនេះ (៨០២-១៤៣៣) ជាសម័យ **ឧត្ដុង្គត** (apogée) នៃអរិយធម៌ខ្មែរ នៃ ប្រទេសមហា អំណាចមួយនៅ អាស៊ីអគ្នេយ៍។យោងតាមឯកសារចិន (លោក ជីវ-តាក្វាន់ ដែលមកទស្សនា ប្រទេសខ្មែរ នៅចុង ស.វ.ទី១៣)មានពន្យល់ប្រាប់យ៉ាងសង្ខេប អំពីលទ្ធិដឹកនាំជាតិ, បរិបទ[7]សាសនា និង ប្រពៃណី នៃជនជាតិខ្មែរ នៅក្នុងជំនាន់នោះ។ វិទូបុរាណវិទ្យា តែងតែ យល់ឃើញថា ផុតពី ចំណេះបូរាណវិទ្យា (au-delà de la connaissance archéologique), ហើយបើគ្មាន ឯកសារប្រវត្តិសាស្ត្រ ណាមួយ សំរាប់បញ្ជាក់បន្ថែម នូវការពិត អំពីអ្វីផ្សេងទៀត លើសពី វត្ថុបូរាណ ដែលជា ប្រធានសិក្សា នោះទេ, គឺជា ការចូលទៅក្នុង វិស័យ មនោគតិ របស់ ប្រវត្តិសាស្ត្រវិទូ នោះឯង។ ហេតុនេះឯង បានជានៅក្នុង ចំណេះប្រវត្តិសាស្ត្រខ្មែរ ក្នុងសម័យអង្គរ មាន ការបកស្រាយ មួយភាគធំ របស់ វិទូបុរាណវិទ្យាមួយចំនួន តាមការយល់ឃើញរបស់គេ រៀងខ្លួន ជាពិសេសក្នុងការបកស្រាយ ចំណារលើ សិលាចារឹក ទាំងភាសាសំស្ក្រឹត និង ខ្មែរបុរាណ។ តែបើមានមូលដ្ឋាន នៃការពិចារណា ប្រហែលគ្នា នៅក្នុងករណីនេះ គេនាំគ្នា សម្រេច ធ្វើការសន្មត (convention) រួមក្នុង **ពិធិសារ** (protocole) សិក្សា។ ក្នុងចំណុចនេះ លោក G. Cœdès, ប្រវត្តិសាស្ត្រវិទូ បារាំងដែល ជាអ្នកឯកទេស នៃប្រវត្តិសាស្ត្រខ្មែរ សម័យមុនអង្គរ និង សម័យអង្គរ បានរំលឹក អំពីបញ្ហាសំខាន់នេះ ដល់អ្នក អានប្រវត្តិសាស្ត្រ សម័យអង្គរ ព្រោះថា ចំណេះ នៃប្រវត្តិសាស្ត្រនេះ ផ្អែកលើ វត្ថុបូរាណ ច្រើនជាង ឯកសារប្រវត្តិសាស្ត្រ។ រូបចម្លាក់ មានលើផ្ទាំងសិលាបង្ហាញឲឃើញ តែផ្នែក ដែលអ្នកដឹកនាំ គេចង់បង្ហាញឲឃើញ ដូច្នេះគំហើញនេះវាមានទិដ្ឋភាពជានយោបាយច្រើនជាង ជាប្រវត្តិសាស្ត្រ។

[6] បទដ្ឋាន=Base។
[7] បរិបទ=Régime។

យើងយល់ថា ក្នុងចំណោះនោះ មាន ការសន្មត ជាច្រើន រវាង ប្រវត្តិសាស្ត្រវិទូ។ ហេតុនេះឯង ប្រវត្តិសាស្ត្រខ្មែរ សម័យអង្គរ មានចរិកលក្ខណៈ ជា គំហើញទូទៅ (vues d'ensemble) ខុសពី ចំណោះ បូរាណវិទ្យា នៃប្រាសាទខ្មែរ ដែលមានចរិកលក្ខណៈ ជាចំណោះ ជាជម្រៅ ព្រោះមាន ការ បែកជាភាគល្អិតល្អន់ណាស់។ តែយើងដឹកថា មនោគតិ របស់ ប្រវត្តិសាស្ត្រវិទូលើ ប្រវត្តិសាស្ត្រ ខ្មែរ គេច្រើន ធ្វើតាម ការប្រៀបធៀបគ្នា រវាង អរិយធម៌ឥណ្ឌា ជាមួយអរិយធម៌ ខ្មែរ-អង្គរ ព្រោះគេយល់ថា អរិយធម៌ ខ្មែរ-អង្គរ បានទទួលឥទ្ធពលខ្លាំងណាស់ ពីអរិយធម៌ឥណ្ឌា។ ទស្សនៈនេះ យើងពុំអាចយល់ស្របតាម ទាំងអស់ បាននោះឡើយ ព្រោះ សង្គមខ្មែរ មុនសម័យ អង្គរ ជាសង្គមមួយ មានរចនាសម្ព័ន្ធសង្គម រឹងប៉ឹងរួចហើយ ដែលមិនអាចទទួល នូវឥទ្ធពល ឥណ្ឌា ឥតមាន ប្រតិកម្មវិភាគ រកភាពប្រសើរជាង យកមក ឬ បន្ត អនុវត្ត នៅក្នុងសង្គម ខ្មែរ ក្នុងពេលមានជំនួប រវាង អរិយធម៌ទាំងពីរ សោះនោះឡើយ។ ប្រតិកម្មបែបនេះឯង ដែល នាំបង្កើតបាន នូវអរិយធម៌ថ្មីមួយ ហៅថា អរិយធម៌អង្គរ ដែលជា សំយោគ រវាង អរិយធម៌ ដើមខ្មែរ និង អរិយធម៌ឥណ្ឌា។ តែដោយសារ អ្នកប្រាជ្ញខ្មែរយើង គ្មានលទ្ធភាព,សមត្ថភាព ឬ ខ្វះសេចក្ដីក្លាហានពោលអះអាង នូវអត្តិភាពនេះ, ការយល់បរទេស វាក្លាយជា សេចក្ដីពិត សំរាប់ ជាតិខ្មែរ។ តែនៅក្នុងឆ្នាំ ២០០៩ លោក សាស្ត្រចារ្យ វេជ្ជវិជ្ជា **ថាច់-ទាន់** បានសរសេរ ហើយ ចុះផ្សាយសៀវភៅដ៏សំខាន់មួយ មានចំណងជើងថា «**ប្រវត្តិសាស្ត្រ ជនជាតិខ្មែរ**[8]» បញ្ជាក់បង្ហាញអំពី ដើមកំណើត និង វប្បធម៌ដើម នៃជនជាតិខ្មែរ។ សៀវភៅនេះ ជាភាគដែលខ្វះ (pièce manquante) មួយ សំរាប់ កូនខ្មែរ យកមកបំពេញ នៅក្នុងចំណោះចេះដឹង នៃ ប្រវត្តិសាស្ត្រ របស់ជាតិខ្លួន។

## ២. ប្រវត្តសាស្ត្រ ផ្នែកសាមញ្ញ

ជាប្រវត្តិសាស្ត្រ សរសេរទុក ជាការចងទុកចំណាំ សំរាប់ កូនខ្មែរ ដោយ បុព្វបុរសខ្មែរ។ ប្រវត្តិសាស្ត្រ នេះ មានគ្រប គ្រប់សម័យ ពី ដើមកំណើត ស្រុកខ្មែរ, សម័យអង្គរ រហូត តមកដល់ សតវត្សទី១៩ តែវិទូប្រវត្តិសាស្ត្រ បរទេស គេមិនឲតម្លៃ ជា វិទ្យាប្រវត្តិសាស្ត្រ នោះឡើយ ព្រោះ វាគ្មានពស្តុតាង សម្ភារៈ និង គ្មានគោលវិធី វិទ្យាសាស្ត្រ ជា គោលវិធីសិក្សា។

តាមឯកសារ ជាអក្សរខ្មែរ នៃក្រុមរាជនិពន្ធ នៃព្រះបរមរាជវាំង នៅដើមសតវត្សទី២០ ឃើញ មាន ប្រវត្តិសាស្ត្រខ្មែរ តាំងពីពីពុទ្ធ សករាជ ១៤៤ មុនគ្រិស្តសករាជ និង ៤00 ឆ្នាំ ក្នុងផែនដី ស្ដេច ចាម សោយរាជ្យ បន្តៗគ្នា ក្នុង នគរគោកធ្លក ខាងភ្នំដងរែក បាន ៥ អង្គ ក្នុង រវាង ១៣៣ឆ្នាំ រួចបានមក ព្រះថោង ស្ដេចពីនគរ ឥន្ទប័ត្ត (ហិណ្ឌូ) គ្រងរាជ្យ ក្នុងពុទ្ធ សករាជ ២៧៧ មុនគ្រិសសករាជ បន្តរាជ្យវង្ស អស់រយៈពេល ២៦៧ ឆ្នាំ។ រួចមានបន្តពី ព្រះ នគរ «**ខេមរៈ**» ជាក្រុងកម្ពុជា រៀងមកដល់ឆ្នាំម្សាញ់ ឯកស័ក ព្រះពុទ្ធស័ក២៤៧២ ត្រូវនឹង

[8] Histoire des Khmers – L'Odyssée du peuple cambodgien : L'édition L'Harmattan។

គ្រិស្តសករាជ ១៩២៩។ សព្វថ្ងៃនេះ ស្តេចខេមរៈ សោយរាជ្យ តៗ មក បានប្រមាណ ៧៣ ព្រះអង្គ (ត្រូវជា៨២ រាជ្យ ព្រោះព្រះមហាក្សត្រអង្គខ្លះ ឡើងសោយរាជ្យច្រើន ពីរដង បីដង មួយព្រះអង្គក៏មាន) ក្នុងរវាងប្រមាណ២១៩៧ ឆ្នាំហើយ មិនទាន់បានបោះពុម្ពនៅឡើយ ដោយហេតុថា ត្រូវពិនិត្យឡើងវិញ ឲត្រឹមត្រូវជាមុន។ តែនៅក្នុងឆ្នាំ ១៩២៨ ព្រះបាទ សម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ទ្រង់ព្រះតម្រិះយល់ថា បើនឹងបង្អង់ បោះពុម្ពនេះតទៅទៀត នឹងយឺតយូរឥតប្រយោជន៏ ទើបបានទ្រង់សុំឲកុង្ស៊ីសេនាបតីជំនុំនឹងលោក រ៉េស៊ីដង្គស៊ុំប៉េរិយ៉េរ ឲបោះពុម្ពជាអក្សរខ្មែរ នូវព្រះរាជពង្សាវតារក្រុងកម្ពុជា តាមសេចក្តីដើម ដែលមានទាំងអស់ ១៣ សៀវភៅ ជាក្រដាស វិចរិល នៅក្នុងក្រុមព្រះរាជនិពន្ធ ដែលបានរក្សាសព្វថ្ងៃនេះជាប្រញាប់ ទុកសំរាប់ព្រះនគរ ចែកទៅសាលារៀន និង ជាវឲអ្នកទាំងពួងបានស្គាល់ព្រះរាជពង្សាវតារ ស្រុករបស់ខ្លួន។

ថ្វីបើ ប្រវត្តិសាស្រ្តខ្មែរ សរសេរដោយខ្មែរ ជារឿងព្រេង, ជាពាក្យកាព្យ, ជារឿងល្ខោនរាំ, ជាឯកសារ**លើសលស់**[9] ជាប្រវត្តិសាស្រ្ត, អាជ្ញាធរ អាណានិគមបារាំង ដែលមាន លោក ឡាវិត ជា រ៉េស៊ីដង្គសុប៉េរិយ៉េរ បានអនុញ្ញាតឲបោះពុម្ភ **ព្រះរាជពង្សាវតារក្រុងកម្ពុជា** គឺប្រវត្តិសាស្រ្តខ្មែរ ក្រោយសម័យអង្គរ តាមរាជសំណើរ របស់ព្រះចៅក្រុងកម្ពុជា។ ព្រះរាជពង្សាវតាក្រុងកម្ពុជា គ្របតាំងពី ផែនដី ឬ រជ្ជកាល ព្រះបាទ ត្រសក់ផ្អែម (១៣៤០?-១៣៤៦)[10] មក ដល់ ព្រះបាទ សម្តេច ស៊ីសុវត្ថិមុនីវង្ស (១៩២៧-១៩៤១) មានរយៈពេល ទាំងអស់ ៦០១ ឆ្នាំ។ ក្រោយពីរជ្ជកាលព្រះបាទ ស៊ីសុវត្ថិមុនីវង្ស គឺ ជារជ្ជកាល ព្រះបាទ នរោត្តម សីហនុ។ ព្រះអង្គឡើងសោយរាជ្យពីរដង គឺ ពីឆ្នាំ ១៩៤១ ដល់ ១៩៥៥ បន្ទាប់មក ឡើងសោយរាជ្យម្តងទៀត ក្នុងឆ្នាំ ១៩៩៣ ដល់ ២០០៤។ លើកទី១ ព្រះអង្គដាក់រាជ្យ ថ្វាយព្រះបិតា ព្រះនាម នរោត្តម សុរាម្រិត (១៩៥៥-១៩៦០) លើកទិ២ ដាក់រាជ្យ ថ្វាយ ព្រះរាជបុត្ត ព្រះនាម នរោត្តម សីហមុនី (២០០៤ មកដល់សព្វថ្ងៃនេះ)។

យើងឃើញថា បណ្ឌិតបូរាណខ្មែរ លោកទុក មរតក ច្រើនណាស់ សំរាប់ជាតិខ្មែរ ជាពិសេសនៅក្នុងវិស័យ ប្រវត្តិសាស្រ្តជាតិ ព្រោះលោកដឹងថា បើកូនខ្មែរ ចេះដឹងអំពី ប្រវត្តិសាស្រ្តជាតិ គឺជា អាវុធនៃបញ្ញាមួយ សំរាប់ថែរក្សាជាតិ និង គំនិតជាតិ ឲបានគង់វង់ និងរុងរឿងបាន។ តែយើងដឹងថា មរតក នៃប្រវត្តិសាស្រ្តជាតិ មានលក្ខណៈ ច្រើនជា រឿងព្រេង ដែលនាំឲអ្នកប្រាជ្ញបរទេសគេទុកជាចំណេះ គ្មានមូលដ្ឋាន ជាវិទ្យាសាស្រ្ត។ បើយើងធ្វើការពិចារណាបន្តិចអំពីរបៀប **មាបទកម្ម** (ការបង្កើត) នៃប្រវត្តិសាស្រ្ត របស់បណ្ឌិតបូរាណខ្មែរ យើងឃើញមានលក្ខណៈចង់ឲមានភាព ជាបណ្តាំ ច្រើនជាង ជាព្រឹត្តិការណ៏ ព្រោះលទ្ធិខ្មែរដើម គោរពវិញ្ញាណម៉ែឪដូនតានិង អ្នកតា។ គេជឿថា បើគេជឿតាមបណ្តាំ ទំនៀមទម្លាប់ ម៉ែ-ឪ ច្បាស់ជាវិញ្ញាណរបស់គាត់នឹងតាមថែរក្សាពួកគេឲបានសេចក្តីសុខចំរើន។ នៅក្នុង **បញ្ញត្តិ**[11] នៃបណ្តាំនេះ នៅពេលដែលជនជាតិខ្មែរ ទទួលយក ព្រាហ្មណ៏សាសនា បន្តមក ពុទ្ធសាសនា មកធ្វើជា ជំនឿរបស់ខ្លួនក៏នៅតែមាន ឥទ្ធពលទៅលើ ការបង្កើតប្រវត្តិសាស្រ្ត ជានិច្ច តែលើកនេះ បណ្ឌិត

[9] លើសលស់= Plus ou moins។
[10] នៅក្នុងឯកសារ «មហាបុរសខ្មែរ» និពន្ធដោយ លោក អេង-សុត ឆ្នាំឡើងសោយរាជ្យ របស់ព្រះបាទត្រសក់ផ្អែម គឺ ៩៨៩ គ.ស. ដល់ ១០៤៨។ ក្នុងចំណុចនេះ លោក បញ្ជាក់ថា លោក ចម្លងពីឯកសារដើម ដោយ មិនដូរឆ្នាំនោះទេ ព្រោះ លោក ចង់រក្សាភាពដើម ដែលមាននៅក្នុងឯកសារបុរាណខ្មែរ។
[11] បញ្ញត្តិ=concept។

បូរាណខ្មែរ លោកបន្ថែម លើគំនិតបណ្ដាំ នូវគំនិតថ្មីមួយទៀត គឺ សីលធម៌នៃសាសនា ព្រោះ បណ្ឌិតខ្មែរ សុទ្ធជាអ្នកកាន់សាសនា ឬ ជា បព្វជិត។ យើងដឹងថា នៅបស្ចិមប្រទេស ក្នុងសម័យ បូរាណ មានសង្គ្រាមគំនិត ដ៏សាហាវ រវាង ទស្សនៈវិទូ ជាមួយនឹង អ្នកកាន់សាសនា អំពីជំនឿ សាសនា និង ការពិចារណា បែបទស្សនៈវិជ្ជា។ ចំពោះ អង្គការសាសនា គំនិតណា ដែលនៅក្រៅ គំនិតសាសនា គេទុកជា **អញ្ញទិដ្ឋ**[12] (hérésie), ឯចំណែក ទស្សនៈវិទូ ទុកជំនឿសាសនា ជា ជំនឿគ្មានការពិចារណា។ ដូចគ្នានឹង ប្រវត្តិវិទូ ទុកប្រវត្តិសាស្ត្រសាមញ្ញខ្មែរ ជា ប្រវត្តិសាស្ត្រគ្មាន មូលដ្ឋានវិទ្យាសាស្ត្រ នោះឯង។

***អ្វីទៅដែលជាមូលដ្ឋានវិទ្យាសាស្ត្រ របស់ប្រវត្តិសាស្ត្រ ?*** ការចេះសង្កេត, ពស្តុតាង ជាសម្ភារៈ, សរសេរ និក្ខេបបទ ពន្យល់ជាលំអិត អំពីគំនិត និង លទ្ធផលរកឃើញ ពីការស្រាវជ្រាវ តាមពិធីសារ វិទ្យាសាស្ត្រ និង **ស្វីការ**[13] ពីសំណាក់ សហគមន៍អ្នកប្រាជ្ញ។

## ប្រវត្តិសាស្ត្រសាមញ្ញខ្មែរ មានអ្វីខ្លះ ?

តើប្រវត្តិសាស្ត្រសាមញ្ញខ្មែរនេះ វាមានផ្លែកអ្វីខ្លះ ពីប្រវត្តិសាស្ត្រ ក្នុងសៀវភៅបរទេស ស្ដីពីប្រវត្តិសាស្ត្រខ្មែរ បែបសង្ខេបខ្លីៗ តែគេបោះពុម្ពមានចំនួនច្រើន ដែលនាំឲ្យប្រវត្តិសាស្ត្រសាមញ្ញខ្មែរ លិបបាត់ទៅៗ ស្ទើរតែតែបាត់អត្ថភាព នៅក្នុងស្រុកខ្មែរ។ ការខុសផ្លែក ជាគំនិតទូទៅ គឺ ទី ១ ដូចយើងបានជំរាបប្រាប់ខាងលើរួចមកហើយ គឺ មាបទកម្ម នៃប្រវត្តិសាស្ត្រ ឈរលើគោល **បណ្ដាំ** និង **សីលធម៌សាសនា** ខុសពី បរទេស គេឈរលើ ព្រឹត្តិការណ៍ មានការ ចុះកាលបរិច្ឆេ-ទ (datation) ច្បាស់លាស់ ដែលគេទុកវា ជាអត្ថរស់ នៃហេតុការប្រវត្តិសាស្ត្រ ដែលមានកំណល់ ពស្តុតាងជាសម្ភារៈ ទុកជាការបញ្ជាក់។ ការខុសផ្លែកមួយទៀត គឺស្ថិតនៅក្នុងអង្គភាព (forme) នៃសម្បយោគ (continu) របស់ ខ្មែរ ប្រៀបប្រដូចនឹង បរទេស។ សម្បយោគ របស់ខ្មែរមានលក្ខណៈ ជារឿងព្រេង សរសេរ ឬ និទាន សំរាប់ ប្រលោមអារម្មណ៍ អ្នកអាន ឬ អ្នកស្ដាប់ ឲជាប់ចិត្តនឹងសាច់រឿង, ឯចំណែក សម្បយោគ របស់បរទេស ជាឯកសារ សំរាប់អាន ដើម្បីការចេះដឹងជាចំណេះ ក៏ដូចជា **ញាណិច្ចតា**។

ប្រវត្តិសាស្ត្រសាមញ្ញខ្មែរ មានចែកចេញជាបីសម័យៈ

- **ដើមកំណើត ស្រុកខ្មែរ**ៈ មានរឿងព្រេងនិទានខ្មែរពីរ ដែលខ្មែរយើង យកមកធ្វើជាចំណេះជាតិ ស្ដីពីដើមកំណើត ទឹកដីខ្មែរ គឺៈ **ព្រះពុទ្ធទំនាយ** និង **ព្រះថោង និង នាងនាគ**។ ព្រះរាជវង្សព្រះថោង មានក្សត្យទាំងអស់៥ព្រះអង្គ ដែលបានសោយរាជសម្បត្តិ បន្តបន្ទាប់គ្នា ចាប់តាំងតែពី ឆ្នាំ២៦៧ មុន គ.ស. រហូតមកដល់ឆ្នាំទី១ មុន គ.ស.។ រាជវង្សនេះ ត្រូវរលត់ពូជ ដោយសារស្ដេចចុងក្រោយបង្អស់ ព្រះនាម ព្រះប្រទេសរាជ គ្មានបុត្រា[14]

[12] អញ្ញទិដ្ឋ=គំនិតប្រឆាំងនឹងជំនឿសាសនា។
[13] ស្វីការ=Acceptation ; ការទទួលព្រម។
[14] រឿងព្រេនាងនិទ

- **សម័យអង្គរ**៖ មានរឿងព្រេងជាច្រើន និទានរៀបរាប់ អំពីដើមកំណើត ប្រាសាទអង្គរ,ដូចយ៉ាង រឿងនិទាន **ព្រះកេតុមាលា** ឬ រឿងល្បើកអង្គរ។ ព្រះកេតុមាលា ជាមហាក្សត្រទី៥ នៃរាជវង្សព្រះថោង។ ខ្មែរយើងចាំឈ្មោះ **ព្រះពិស្ណុការ** ដែលព្រះឥន្ទ្រាធិរាជ បានចាត់ចែង បញ្ជា ឲចុះមកចាំកំណើត ក្នុងឋានលោកកីយ ដើម្បីកសាងប្រាសាទអង្គរ ក្នុងឋានៈជា ព្រះវិស្សកម្មទេវបុត្រ ជាមួយទេវបុត្រចំនួន ៥០០នាក់ទៀត។ មានរឿងនិទានច្រើនទៀត ទាក់ទងនឹងសម័យអង្គរ ដូចយ៉ាង រឿង **តាព្រហ្ម**, **ពញារោង**, **ព្រះបាទបទុមវរវង្ស**, **ព្រះកែវមរកត**, **ព្រះបាទធនញ្ជ័យគោរពរាជ្យ**, **ស្តេចគំលង់**, **បក្សីចាំក្រុង**, **ស្តេចពាល**[15]។ បញ្ហាដែលនាំឲប្រវត្តិសាស្ត្រវិទូ គេពុំទទួលស្គាល់ រឿងនិទានទាំងនោះ ជាប្រវត្តិសាស្ត្រពិតប្រាកដ គឺ ភាពមិនច្បាស់លាស់ នៃកាលបរិច្ឆេទ និង គ្មានពស្តុតាងជាសម្ភារៈ ទុកជាការបញ្ជាក់ ហើយជាពិសេស វាមានលក្ខណៈច្រើនជាអបិយជំនឿ ដូចយ៉ាង ការកសាងប្រាសាទអង្គរវត្ត ជាឧទាហរណ៍។

- **សម័យក្រោយអង្គរ**៖ គឺមាន ព្រះរាជពង្សាវតារខ្មែរ, បោះពុម្ភផ្សាយជាសាធារណៈ នៅក្នុង ឆ្នាំ ១៩២៨ ហើយមានដំកល់ទុកក្នុងព្រះរាជបណ្ណាល័យ។ ក្នុងព្រះរាជពង្សាវតារ សរសេរជាភាសាខ្មែរ ចាប់ពីរាជ្យ ព្រះបាទ ត្រសក់ផ្អែម ឬ អង្គជ័យ (១៣៤០-?) មកដល់រាជ្យ ព្រះបាទស៊ីសុវត្ថិមុនីវង្ស (១៩២៧-១៩៤១)។

យើងឃើញថា នៅក្នុង ប្រវត្តិសាស្ត្រសាមញ្ញនេះ អាចគ្រប លើសលាស់[16] ប្រវត្តិសាស្ត្រជាតិខ្មែរ សំរាប់ជនជាតិខ្មែរបាន ទោះបីវាគ្មានលក្ខណៈជាប្រវត្តិសាស្ត្រវិទ្យាយ៉ាងណាក៏ដោយ។ ត្រង់ចំណុចនេះឯង ដែលអាចបញ្ជាក់បានថា បណ្ឌិតបូរាណខ្មែរ មិនដែល មិនរវល់យកចិត្តទុកដាក់ អំពីប្រវត្តិសាស្ត្រជាតិខ្លួននោះឡើយ, ហើយពីជំនាន់មួយទៅជំនាន់មួយទៀត អ្នកប្រាជ្ញខ្មែរយើងលោកនៅតែងតែបន្ត រក្សា មរតកជាតិ នេះឲបានគង់វង់ជានិច្ច សំរាប់អានាគតកាលជាតិ ហេតុនេះឯង ដែលនាំឲជនជាតិខ្មែរ ដឹង ហើយនិយាយបន្តៗគ្នាថា ខ្លួនជា ជាតិសាសន៏ ជាម្ចាស់ដើម នៃទឹកដី សុវណ្ណភូមិ ដែល ជា នគរ ធ្លាប់រុងរឿង មានអារ្យធម៏ខ្ពង់ខ្ពស់។ អតីតកាលប្រកបដោយកិត្តិគុណនេះឯង ដែលជនជាតិខ្មែរ តែងតែយកមកធ្វើយោង នៃអត្ថិភាព នូវទេពកោសលរុងរឿង នៃជាតិសាសន៏ខ្លួន។

តែក្រោយពីសតវត្ស ទី១៥មក នគរខ្មែរជួបប្រទះ នូវ កលិយុគ គ្រប់បែបយ៉ាង ដែលនាំឲជាតិចុះអន់ថយដល់កំរិតមួយ នាំរំលាយកម្លាំងជាតិឲរលត់សូន្យ ធ្លាក់ខ្លួនជាជាតិខ្ញុំគេ គ្មានលទ្ធភាព នឹងអាចងើបតស៊ូតតាំង ប្រឆាំងទល់ នឹងកលិយុគនេះ។ អស់រយៈ៥សតវត្ស ជាតិសាសន៏ខ្មែរ រស់ក្នុងស្ថានភាពអត្តង្គតជាតិ នាំទៅរក **សតិវិប្បវាស**[17] ដើរលើផ្លូវ ចាញ់សត្រូវជាតិ ជានិច្ចហើយនាំគ្នាបោះបង់គំនិតតស៊ូតតាំង ហើយយកគំនិត កម្មវាសនាគេចមិនផុត (fatalité)មកធ្វើជា ការលួងចិត្ត សំរាប់បន្តរស់ នៅក្នុងសមុទ្រទុក្ខ របស់ខ្លួន។

[15] រឿងព្រេងនិទានទាំងឡាយនោះ លោក រស់-ចន្ត្រាបុត្រ បានសរសេររៀបរាប់ ជាភាសាខ្មែរ ក្នុងសៀវភៅមួយមានចំណងជើងថា៖ ប្រវត្តសាស្ត្រខ្មែត-Edition l’Harmattan។
[16] លើសលាស់=Plus ou moins។
[17] សតិវិប្បវាស=Perte de mémoire, បាត់សតិ។

**អំពីបញ្ហា ការចុះកាលបរិច្ឆេទ**

គួរកត់សំគាលថា សម័យ យុគកណ្តាល នៅបស្ចិមប្រទេស មានពេលវេលាពីរខុសគ្នាៈ ពេលវេលា សាសនានិង ពេលវេលា អ្នកជំនួញ។ ចំពោះ សាសនា ពេលវេលា មានតែមួយគត់ គឺពេលវេលា របស់ព្រះ ហើយទុកពេលវេលា អ្នកជំនួញ ជាពេលវេលាគិតតែរកចំណេញ គឺជា វត្ថុ នៃកម្រៃ[18] តែសាសនា មានការអត់អោនច្រើន ក្នុងវិស័យអនុវត្តន៏ ក្នុងការរស់នៅរបស់មនុស្ស តែនៅតែរក្សាភាពតឹងរឹងជានិច្ច ក្នុង វិស័យ ទ្រឹស្តី។ ចំពោះសាសនាគ្រិស្ត ពេលវេលា ជាពេលវេលា របស់ព្រះ គឺមានកំណើតឡើងពីព្រះ (Dieu) ហើយ គ្របសង្កត់ដោយព្រះ។ ដូច្នេះ គ្រប់សកម្មភាពនៃមនុស្សលោកទាំងអស់ គឺផ្ជាប់ជាជម្មជាតិជាមួយនឹង អំពើរបស់ព្រះទាំងអស់។ ពេលវេលាព្រះជា អនន្តភាព[19](ចិរកាល) ហើយ អនន្តភាពនេះ ជាដំណើរបន្តគ្នាមិនដាច់ នៃពេលវេលា (aiônes[20]) ឬ ចន្លោះពេល ឥតមានកំរិត[21] គឺថា រយៈពេលគ្មានកំណត់ហើយមិនអាចរាប់បាន។ តែ ព្រះ មានពេលវេលា របស់ព្រះអង្គមួយទៀត គឺ ពេលវេលា «បេសកកម្មរបស់ព្រះអង្គ» សំរាប់សង្រ្គោះមនុស្សលោក តែនៅពេលជាមួយគ្នានោះដែរ មនុស្សលោក ក៏មាន ពេលវលារួម និង សំរាប់ខ្លួនឯង សំរាប់ បំពេញបង្ហើយ នូវប្រវត្តិសាស្រ្តរួម និង ប្រវត្តិសាស្រ្តរបស់ខ្លួនផ្ទាល់ ដែរ។ ក្នុងចំណុចនេះ សាសនាលើកយកចំណោទ មកចោទ អំពី «អវសាននៃពេលវេលា ឬ មនុស្សលោក» ដល់ ពួកអ្នកមានជំនឿថា ព្រះនឹងបញ្ជូនទេវតា មកឋានលោកីយ ដើម្បីសង្រ្គោះមនុស្ស ដូចខ្មែរយើងខ្លះមានជំនឿថា មានព្រះបាទធម្មិក ចុះពីឋានសួគ៍មករំដោះខ្មែរ ពីទុក្ខភ័យគ្រប់ប្រការ។ ដូច្នេះការរង់ចាំនេះ ជាពេលវេលា មានន័យ, មានទិសពិត សំរាប់មនុស្ស គឺ លូកដៃ សុំជំនួយពីព្រះ ដែលជាពេលវេលាអនន្តភាព។ តែសាសនា ចាំបាច់មានការវិវឌ្ឍន៏ តាម ស្ថានភាព សេដ្ឋកិច្ចនិងសង្គមកិច្ច នៃសង្គមថ្មីរបស់មនុស្សលោក ដែលនាំបង្កើតឲមាន ពេលវេលាថ្មី គឺ ពេលវេលានៃប្រវត្តិសាស្រ្ត របស់មនុស្សលោករួម និង មនុស្សលោកម្នាក់ៗ។ តែសាសនា ទទួលស្គាល់ ពេលវេលា នៃប្រត្តិសាស្រ្ត ទុកជា ដើមគំនិត នៃព្រះ ថាជាពេលវេលា នៅក្នុង ពេលវេលា ដែលព្រះអង្គ ត្រូវការដើម្បីសង្រ្គោះមនុស្ស។ ដូច្នេះ យើងឃើញថា ពេលវេលាមនុស្សលោក មានទំហំ នៃការសង្រ្គោះរបស់ព្រះជានិច្ច។ តែទស្សនៈនេះ វាចោទជាបញ្ហា ដល់សម័យទំនើប អំពី ***វគ្គិករណ***[22] (ការចាត់ជាពួក, ជាថ្នាក់) ឧបករណ៏សំរាប់ដាក់ជាលំដាប់ និង លទ្ធភាព នៃ **សន្ទិយោគ** (articulation) ដើម្បីផលិតប្រវត្តិសាស្រ្ត។ ការពិចារណា លើចំណោទនេះឯង ដែលនាំបង្កើតគំនិតថ្មីមួយ អំពីប្រវត្តិសាស្រ្ត។ គំនិតថ្មីនេះ គឺទុក ប្រវត្តិសាស្រ្ត ជាចំណេះ វិទ្យាសាស្រ្ត ៖ ឧទាហរណ៏: ប្រវត្តិសាស្រ្ត នៃអារ្យធម៏ ជា **ការបន្តដំណើរគំនិត** (translations) ពីកន្លែងមួយទៅកន្លែងមួយទៀត។ ក្នុងសញ្ញាណ នៃការបន្តដំណើរគំនិតនេះ មានទិដ្ឋភាពដែលគេស្គាល់ច្បាស់ណាស់ គឺ៖ តាម លំដាប់បញ្ញា, មានទ្រឹស្តី កើតឡើងមួយ គឺទុក «**ប្រវត្តិសាស្រ្ត ជាចំណេះ វិទ្យាសា**

[18] វត្ថុនៃកម្រៃ=Objet de lucre។
[19] អនន្តភាព= Eternité។
[20] Aiône : **Aiôn** ou **Aïon** est un terme tiré du grec ancien (Aἰώv) aux acceptions multiples qui signifie « destinée », « âge », « génération », « éternité ». En philosophie antique, il s'agit de l'un des trois principaux concepts du temps, avec *chronos* et *kairos*.
[21] Nouveau testament.
[22] វគ្គិករណ=Classification។

**ស្ត្រ**» ឆ្លងពីក្រុង អាតែន មក ទីក្រុង រូម បន្ទាប់ មក ដល់ប្រទេសបារាំង ហើយ វាបានជ្រួតជ្រាប នៅក្នុងមហាវិទ្យាល័យល្បី នៅក្នុងទីក្រុង បារីស តាំងពីជំនាន់ រាជវង្សស្តេចការូលិន (៥៨២-៩៨៧)មកម្លេះ។ ប្រវត្តិសាស្ត្រ មានទិដ្ឋភាព ជាវិទ្យាសាស្ត្រនេះ គឺវាមានលក្ខណ: លើសអំពី **សីលធម៌** ដែលជាកញ្ចក់ នៃមហាក្សត្រ មកជា **វិទ្យាសាស្ត្រ នៃអំណាច** នៅក្នុងរដ្ឋមួយ ដែលរៀបចំឡើង ជាអង្គកាយ មានគោលបំណង មានរដ្ឋបាល ជាមូលដ្ឋាន សំរាប់ទ្រទ្រង់ នូវគ្រប់កិច្ចការដែលរដ្ឋត្រូវធ្វើ លើសពី ការគិតតែពី បំរើ ពួកសក្តិភូមិ[23]។

ចំណុចវិទ្យាសាស្ត្រនេះហើយ ដែលប្រវត្តសាស្ត្រវិទូ លើកមកចោទជាបញ្ហា ដល់បណ្ឌិតបូរាណខ្មែរ ថាផលិត នៃព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ ដោយគ្មានបញ្ជាក់ការចុះកាលបរិច្ឆេទពិតប្រាកដ។

ត្រូវដឹងថា ក្នុងសម័យបូរាណខ្មែរ សញ្ញាណ នៃពេលវេលាប្រវត្តិសាស្ត្រ មិនដូចគ្នានឹង សញ្ញាណ នៃពេលវេលា សព្វថ្ងៃនេះទេ ដែលគេឲឈ្មោះថា «ពេលវេលា នាឡិកា»។ ពេលវេលាក្នុងសម័យដើមខ្មែរ ជាចំនួន នៃចលនា របស់បុគ្គលម្នាក់ៗ ហេតុនេះឯងហើយ បានជា ពេលវេលា បែបនេះ វាខុសពី ពេលវេលា នៃធម្មជាតិ ដែលខ្មែរយើងឲឈ្មោះថា «រដូវ»។ រួមសចក្តីមក យើងអាចសន្និដ្ឋានបានថា រដូវ ជាពេលវេលារួម របស់មនុស្សលោក តែ «ចំនួនចលនា» ជា ពេលវេលាផ្ទាល់ របស់បុគ្គលម្នាក់ៗ។ យើងដឹងថា ប្រវត្តិសាស្ត្រខ្មែរ ច្រើនជាប្រវត្តិសាស្ត្រ ស្តីអំពី គុណសម្បត្តិរបស់មហាក្រត្យ ហេតុនេះឯង បានជាមាន ទំហំ (dimension) បុគ្គលលើសលុបនៅក្នុងប្រវត្តិសាស្ត្រខ្មែរ។ បណ្ឌិតបូរាណខ្មែរយើង គាត់មិនសូវយកចិត្តទុកដាក់អំពី ពេលវេលានោះឡើយ ព្រោះជំនាន់ដើម គ្មាន ឯកភាពសំរាប់វាស់ពេលវេលាផង និង គ្មានពេលវេលាណាមួយអាចមានតម្លៃលើសពីសកម្មភាពរបស់មហាក្សត្រផងៈ បើព្រះអង្គ ចង់បាន ចង់ធ្វើអ្វីមួយ សារៈសំខាន់ គឺ លទ្ធផលនូវទីបញ្ចប់ ដែលមិនត្រូវមានការបង្ខិតបង្ខំ អំពីពេលវេលាណាមួយនោះឡើយ។ យើងអាចសន្និដ្ឋានបាន ពេលវេលារបស់ព្រះមហាក្សត្រ នៅជំនាន់បូរាណ គឺជាពេលវេលា អនន្តភាព នោះឯង។

## ៣. ប្រវត្តសាស្ត្រ ថ្មី[24]

ប្រវត្តិសាស្ត្រថ្មី (récente) គឺ មានចាប់ពីសម័យ បញ្ចប់សង្គ្រាមលោក លើកទី២ មកដល់បច្ចុប្បន្នកាលនេះជាប្រវត្តិសាស្ត្រ គ្របដោយព្រឹត្តិការណ៍នយោបាយជាតិ។ មានព្រឹត្តិការណ៍សំខាន់ជាច្រើន មានកើតឡើងនៅស្រុកខ្មែរៈ ការទាមទារឯករាជ្យពីបារាំង, ពន្លកនៃលទ្ធិប្រជាធិបតេយ្យ, ស្តេចសីហនុ, របបសាធារណរដ្ឋ, ខ្មែរក្រហម, អាណានិគមយួន, ដំណើរខ្មែរថ្មី និង បរាជ័យលទ្ធិប្រជាធិបតេយ្យសេរី។

23 ឯកយោងៈ Le Goff – Un autre Moyen Âge : Edition Quarto GALLIMARD។
24 ប្រវត្តិសាស្ត្រថ្មី=Histoire récente។

ព្រឹត្តិការណ៍ទាំងឡាយនេះ មានហេតុការ (faits) ច្បាស់លាស់ មានកាលបរិច្ឆេទពិត មានពស្តុតាង ជាសម្ភារៈ សំរាប់បញ្ជាក់ តែខ្មែរយើង ឥតមើលឃើញ ឬ យល់ឃើញ នៃសាច់រឿង នៃព្រឹត្តិការណ៍ដូចគ្នានោះឡើយ ព្រោះជារឿងនយោបាយ។ ឧទាហរណ៍ ស្ដីអំពី ការទម្លាក់ ស្ដេចសីហនុ ពីដំណែង ប្រមុខរដ្ឋ ដោយ សភាជាតិ, ខ្មែរយើងខ្លះ ទុកទង្វើនេះ ជារដ្ឋប្រហារ អ្នកខ្លះទៀត ទុកជា ការស្របច្បាប់, ហើយម្ខាងៗសោធទៀត បែជានាំគ្នាដើររក សំដី ឬ ការសរសេរ របស់ជនបរទេស ល្បីល្បាញ មកធ្វើជាយោង សំរាប់ការយល់ឃើញរបស់ខ្លួន ជាជំនួស នូវការពិចារណា ប្រកបទៅដោយ **វិស្សុសៈភាព** (sincérité) របស់ខ្លួនទៅវិញ ឬ តាមបែបទស្សនវិជ្ជា។ នៅមានឧទាហរណ៍ជាច្រើនទៀតដូចយ៉ាងព្រឹត្តិការណ៍ថ្ងៃទី៧មករា ឆ្នាំ១៩៧៩ ។ល។ តើការពិត មាននៅត្រង់ណា ?

តែក្នុងប្រវត្តិសាស្ត្រថ្មីនេះ វាមានលក្ខណៈពិត របស់វាមួយ គឺ ការបង្ហាញនូវភាព ប្រេះបែក ជាកំទេច របស់សង្គមខ្មែរ នាំឲខ្មែរ ប្រខាំគ្នា ដើម្បីបោយរកប្រយោជន៏រៀងៗខ្លួន។ សត្រូវរួម របស់ខ្មែរបច្ចុប្បន្នកាលនេះ គឺ ខ្មែរខ្លួនឯង តែម្ដង។ ជាតិខ្មែរបាក់បែក ខ្សោយខ្សោះអស់ទៅហើយ តើនៅសល់អ្វី ដែលអាចស្ដារគំនិតខ្មែរ ឲចេះមាន មេត្តា ករុណា ស្រឡាញ់រាប់អានគ្នា សាមគ្គីរួបរួមជិតស្និទ្ធគ្នាឡើងវិញ ? ពុទ្ធសាសនា ? ចំពោះ **ភិក្ខុ ងិន-ភេង**[25] បើជាតិខ្មែរនិងប្រជាជនខ្មែរស្អប់បោះបង់សាសនានេះចោលទៀត គឺរឿងខ្មែរ វាចប់ត្រឹមហ្នឹងហើយ។ នេះ ជាល្បិចនៃបរទេស។ ព្រះអង្គ មើលឃើញតម្លៃនៃសសានា សំរាប់ជាតិខ្មែរ ព្រោះយើងមើលឃើញដែរ បើយកប្រវត្តិសាស្ត្រ មកធ្វើជាកញ្ចក់ សំរាប់ ឆ្លុះមើលសង្គមខ្មែរ គឺថាក្រៅអំពី ទិដ្ឋិ(dogme) នៃពុទ្ធសាសនា គឺគ្មាន **ប្រព័ន្ធតម្លៃ**[26] ណាមួយផ្សេងទៀត ដែលអាចទុកបាន ជាការតាក់តែងក្នុងផ្នែកសីលធម៍ លើសពីពុទ្ធសាសនា។ ដូចលោក វ៉ាន់-ឌិកាអុន ដែរ, លោកមាន យោបល់ម្យ៉ាងមួយទៀត ថា នៅក្នុងសង្គមខ្មែរ ខ្វះ ទស្សវិជ្ជា សំរាប់ ឲជនខ្មែរ ចេះពិចារណា អំពី សីលធម៍ និង អសីលធម៍ ដែលនាំឲជនខ្មែរជួបប្រទះវិបត្តិច្រើនក្នុងគតិ។ គួរកត់សំគាល់ថា ទស្សនវិជ្ជាទេពនិយម[27] ឬ ធម៍នៃសាសនា ជាទិដ្ឋិសំរាប់ជឿដាច់ខាត ឯចំណែកទស្សនវិជ្ជា បស្ចិមប្រទេស ជាការត្រិះរិះ សំរាប់យកមកធ្វើការពិចារណា រកហេតុផល។ ទស្សនវិជ្ជាទាំងពីរបែបនេះ សុទ្ធតែសារប្រយោជន៏ដូចគ្នាសំរាប់មនុស្សលោក ក្នុងវិស័យសីលធម៍ ដែលរស់នៅក្នុងសង្គមសក្តិភូមិ ដែលមាន សីលធម៍អំណាចផ្ដាច់ការ ជាទិដ្ឋិ សំរាប់ឲប្រជារាស្ត្រគោរពដាច់ខាត។ នៅក្នុងសង្គមខ្មែរ បែបសក្តិភូមិ គ្មានទស្សនវិជ្ជា ហើយ បើខ្មែរ នាំគ្នាបោះបង់ជំនឿលើពុទ្ធសាសនាទៀត គឺខ្មែរ វាចប់ត្រឹមហ្នឹងឯង ដូច ភិក្ខុ ងឹន-ភេង ព្រះអង្គ មានយោបល់នោះឯង។

ប្រវត្តិសាស្ត្រថ្មីខ្មែរ មានលក្ខណៈជាលទ្ធិ ខុសពី លក្ខណៈ ប្រវត្តិសាស្ត្រសាមញ្ញ ដែលមាន គ្រិះ ជាបណ្ដាំ និង សីលធម៍សាសនា។ លទ្ធិជាគំនិតរបស់កប្បពួក បង្កើតឡើង សំរាប់ការពារបក្សពួក ហេតុនេះឯង យើងពុំអាចទុកប្រវត្តិសាស្ត្រថ្មី ជាប្រវត្តសាស្ត្រ ក្នុងន័យ វិទ្យាប្រវត្តិសាស្ត្របាននៅឡើយ វានៅមានលក្ខណៈត្រឹមជា ព្រឹត្តិការណ៍ សង្គមក្ដី នយោបាយក្ដី។ ម្យ៉ាងមួយទៀត

[25] ដកស្រង់ពីប្រធានសិក្សារបស់ព្រះអង្គ នៅក្នុង សិក្ខាសីលាមួយ: សាសនា និង ជាតិខ្មែរ។
[26] ប្រព័ន្ធតម្លៃ= Le système de valeur។
[27] ទស្សនវិជ្ជាទេពនិយម=Philosophie panthéistique។

ខ្មែរយើង ខ្វះ ឬ គ្មាន ប្រវត្តិសាស្ត្រវិទូណាមួយ មានកិត្តិនាម (notoriété) ជាអ្នកឯកទេស មានស្នាដៃ ផលិត ប្រវត្តិសាស្ត្រជាតិ អាចឲខ្មែរដ៏ទៃទៀត ទុកស្នាដៃនោះ ជា យោង សំរាប់ខ្លួន ព្រោះនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន មានពុះគំនិតខ្មែរ ជាច្រើនលទ្ធិនយោបាយ ដែលនាំឲខ្មែរ មានការសង្ស័យ គ្រប់បែបយ៉ាង ទៅលើ **វិស្សុសភាព** (sincérité) និង **អនាគតិ** (impartialité) របស់អ្នកចេះដឹងខ្មែរ។ នៅក្នុងសង្គមខ្មែរ បច្ចុប្បន្ន «មូលធន នៃ សេចក្តីទុកចិត្ត[28]»រវាងខ្មែរ នឹង ខ្មែរ វាធនក្ស័យ អស់ទៅហើយ។

ហេតុនេះឯង បានជា ខ្មែរយើង យល់ឃើញថា ប្រវត្តិសាស្ត្រថ្មី គឺជា មតិនយោបាយរបស់បក្សពួកនិមួយៗ តែប៉ុណ្ណោះ។ ឧទាហរណ៍ ដូចយ៉ាង ខៀវ-សំផន, ជាជន ជាប់ចោទពីបទប្រព្រឹត្តអំពើ ប្រឆាំងនឹងមនុស្សជាតិ, សរសេរសៀភៅអំពី ប្រវត្តិសាស្ត្រថ្មី នៃកម្ពុជា[29] នៅក្នុងនោះគាត់កែ ហេតុការណ៍ នៃ ព្រឹត្តិការណ៍ ដើម្បីបំផុង ឲខ្មែរ យល់ច្រឡំ ពីគោលបំណង ដ៏ចង្រៃ របស់គាត់ គឺ ការបំផ្លាញជាតិខ្មែរ។

ប្រវត្តិសាស្ត្រសម័យ ទោះបីសរសេរ អំពីព្រឹត្តិការណ៍ថ្មីក្តី ឬ លើក យកឯកសារបូរាណមកសរសេរឡើងវិញក្តី ច្រើនតែមានគោលដៅជា សហត្ថាករណ៍ (manipulation) គ្រប់បែបយ៉ាង ដើម្បីស្វែងរកប្រយោជន៏ ឬ ការពារអ្វីមួយ ដែលអ្នកប្រវត្តិសាស្ត្រក្តី អ្នកចូលចិត្តប្រវត្តិសាស្ត្រក្តីចង់បាននៅសតិរបស់ខ្លួន។ គំនិតនេះ ជាកញ្ចក់ឆ្លុះរូបភាព នៃសង្គមខ្មែរបច្ចុប្បន្នដែលកំពុងរស់នៅក្នុង ភាពច្របូកច្របល់ លែងស្គាល់អ្វី ដែលជាប្រយោជន៏ជាតិ អ្វីដែលជាអំពើបំផ្លាញជាតិ។

---

[28]Capital de confiance.

[29] Histoire récente du Cambodge et mes prises de position – Khieu Samphan : Edition L'Harmattan។

# សេចក្ដីសន្និដ្ឋាន

ខ្មែរមានប្រវត្តិសាស្ត្រជាតិពិតមែន តែប្រវត្តិសាស្ត្រនេះ មានការចាត់ជាថ្នាក់ជាតម្លៃ សំរាប់ជនបរទេស, អ្នកចេះដឹងខ្មែរ, ជនសាមញ្ញខ្មែរ ដែលវា នាំបង្កើតឲមាន ការសង្ស័យ រវាង ថ្នាក់តម្លៃនិមួយៗ ហើយជាពិសេស អ្នកនយោបាយខ្មែរ គាត់ច្រើនយកប្រវត្តិសាស្ត្រ មកធ្វើ សហគ្គាករណ៏ សំរាប់បំរើប្រយោជន៏នយោបាយ របស់គាត់។ ដូច្នេះ ពីរបបនយោបាយមួយ ទៅ របបមួយ អ្នកកាន់អំណាច គាត់មិនដែល យកប្រវត្តិសាស្ត្រជាតិ មក លាតត្រដាងឲល្អិតល្អន់ ក្នុងកម្មវិធីសិក្សា គ្រប់ថ្នាក់សិក្សា ពី មធ្យមសិក្សា ដល់ ឧត្តមសិក្សា សំរាប់ យុវជន។ រហូតមកដល់បច្ចុប្បន្នកាល ក្នុង ចំណោមអ្នកស្នេហាជាតិ គាត់មាន តែគំនិតមមៃ (obsession) មួយគត់ក្នុង បរិបទ ស្ថានការជាតិសព្វថ្ងៃ គឺ ខ្មែរ ជាជាតិសាសន៏ ទទួលគ្រោះថ្នាក់ពីប្រទេសជិតខាងដូច្នេះត្រូវនាំគ្នា ក្រោកឈរឡើង ដោយយក សម័យ ព្រះបាទជ័យវ៌្មន ទី៧ មកធ្វើជា លំអានដើម្បីរំដោះជាតិ អំពីការឈ្លានពានបរទេស។ តែខ្មែរយើង ឥតស្គាល់អ្វីឲបានច្បាស់លាស់ ថាលំអាន នោះមាន អន្តរវត្ថុ (contenu) បែបណាផង ក្រៅពី ដឹង តាមឯកសារបរទេស គឺ ការវាតទឹកដីខ្មែរ និង កសាងប្រសាទប្រកបដោយសោភ័ណភាព តែប៉ុណ្ណោះ។ តើអ្នកស្នេហាជាតិខ្មែរបានចោទជាសំណួរដែរឬទេថា សង្គ្រាមវាតទឹកដី របស់មហាក្សត្យខ្មែរ ជា ឆន្ទះរបស់ពលរដ្ឋខ្មែរ ឬ ជា មហិច្ឆិតា របស់មហាក្សត្យ ? តើប្រជារាស្ត្រខ្មែរ ទទួលផលវិបាកបែបណាខ្លះ អំពីនយោបាយ មហាសំណង់ប្រាសាទទាំងឡាយ របស់មហាក្សត្យខ្មែរ ? តើប្រាសាទទាំងនោះមានសារៈប្រយោជន៏អ្វីខ្លះ សំរាប់ជាតិខ្មែរ ក្នុងសម័យនោះ ?

ក្នុងប្រវត្តិសាស្ត្រ បញ្ជាក់ឲខ្មែរយើងដឹងច្បាស់ថា ប្រទេសខ្មែរ មានទឹកដី ជាប្រវត្តិសាស្ត្រ របស់ខ្លួន ទាំងខាង លិច និង ខាង កើត នៃនគរខ្មែរបច្ចុប្បន្ន ដូចមានខេត្តជាច្រើនរបស់ខ្មែរដែលសព្វថ្ងៃ ក្លាយជា ខេត្ត របស់ប្រទេសសៀម, កម្ពុជាក្រោម ក្លាយជា ខេត្ត របស់ប្រទេសយួន។ តើអ្នកជាតិនិយមខ្មែរ មានគោលបំណងអ្វីមួយច្បាស់ដែរឬទេ ថាខ្មែរយើង ចង់បានអ្វីពិតប្រាកដ ក្នុងរឿង ទឹកដីជាប្រវត្តិសាស្ត្រខ្មែរ ? ទាមទារយកមកបញ្ចូលក្នុងទឹកដីខ្មែរបច្ចុប្បន្នវិញ ? ឬ គ្រាន់ឲតែប្រទេស សៀម និង យួន ទទួលស្គាល់តាមការប្រកាសជាផ្លូវការថា ទឹកដីនេះជាទឹកដី ជាប្រវត្តិសាស្ត្រ របស់ជាតិសាសន៏ខ្មែរ ? តើខ្មែរកណ្ដាលយើងបច្ចុប្បន្ន មានគុណសម្បត្តិដ៏ប្រពៃបែបណា ដែលអាចទាក់ចិត្ត ជាតិសាសន៏ខ្មែរ រស់នៅក្នុងប្រទេសសៀម និងយួន ឲមានចំណង់ចង់ មករស់នៅជាមួយខ្លួន ? សព្វថ្ងៃនេះ យើងឥតដឹងអ្វីទាំងអស់ អំពីបញ្ហាទាំងនេះ គិតតែពីយក តណ្ហា និង ការរំជួលចិត្ត មកធ្វើជា ការទាមទារមួយ ដែលគ្មានគោលដៅពិតប្រាកដ។ យើងដឹងថា បញ្ហានេះ ជា ពិសិទ្ធកម្ម (tabou) សំរាប់អ្នកជាតិនិយមខ្មែរ បើនរណាហ៊ានលើកយកមកចោទជា សំណួរ គឺ គេនាំគ្នា ទុក ជននោះ ជាជន មិនស្រឡាញ់ជាតិ ឬ ជា អ្នកក្បត់ជាតិតែម្ដង។ ការលើកយកវាមក ចោទជាសំណួរ មិនមានន័យថា មាន

គំនិត ជតានិយម[30]នោះឡើយ ផ្ទុយទៅវិញ ជាការស្វែងរក ការពិតមួយ ដែលនាំ កុំឲខ្មែរយើង និយាយភ្លូយ (ឥតគិត) ហើយ ដើរតែតាមផ្លូវលំ ដដែលៗ ដែលនាំឲជាតិខ្មែរយើង ធ្លាក់ក្នុង រណ្តៅទុក្ខ អស់ច្រើនសតវត្សរួចមកហើយ។

ប្រវត្តិសាស្ត្រជាតិសាសន៍ខ្មែរ ជាប្រវត្តិសាស្ត្រមួយ មិនទាន់ ចប់នៅឡើយនោះទេ ផ្ទុយទៅវិញជាប្រវត្តិសាស្ត្រ ទើបតែមានកំណើត នៅក្នុង គតិខ្មែរ (esprit khmer) ព្រោះ ប្រទេស និង ជាតិសាសន៍ខ្មែរ កំពុងជួបប្រទះ ជាថ្មី នូវគ្រោះថ្នាក់ បាត់បង់ ជាតិខ្មែរ។ គ្រោះថ្នាក់នេះ ត្រូវចាំបាច់ឲអ្នកស្នេហជាតិ មាន ការមើលថ្មី ទៅលើប្រវត្តិសាស្ត្រជាតិ និង ការត្រិរិះ (pensée) ថ្មី ទៅលើ ជោគ(atout) ដែលខ្មែរយើងមានពិត សំរាប់ រកដំណោះស្រាយ សមតាម បញ្ហា ចោទដល់ជាតិរបស់ខ្លួន។ ការមើកថ្មី ទៅលើ ប្រវត្តិសាស្ត្រជាតិ គឺ ដើម្បីរក ឲឃើញ ព្រលឹងខ្មែរពិត របស់ជាតិ។ មកដល់សព្វថ្ងៃនេះ អ្នកប្រវត្តិសាស្ត្រ ច្រើនតែនាំគ្នា ចំឡងឥតពិចារណា ពីឯកសារ ប្រវត្តវិទូបរទេស ដែលជាការសិក្សា បែបសង្ខេបបំផុត បង្ហាញតែទិដ្ឋភាពទូទៅ តែប៉ុណ្ណោះ ដូច្នេះខ្មែរត្រូវការ អ្នកប្រវត្តិសាស្ត្រខ្មែរ មាន ទេពកោសល្យ មាន កិត្តិសព្ទ សំរាប់ ផលិត ប្រវត្តិសាស្ត្រជាតិ សំរាប់យុវជនខ្មែរ ដែលកំពុង រស់នៅក្នុង សង្គមពហុសាសន៍ ទោះបីខ្លួនចង់ក្តី ឬ មិនចង់ក្តី ព្រោះបរាជ័យ ជាតិខ្មែរ បន្តមិនមិនចេះចប់ អស់ច្រើនសតវត្សមកហើយ នាំបង្កើត សង្គមបែបនេះ។ សព្វថ្ងៃនេះ អ្នកឈ្នះ គឺអ្នកដឹកនាំជាតិសាសន៍យួន គេកំពុងនាំគ្នាសរសេរប្រវត្តិសាស្ត្រខ្មែរ សំរាប់ខ្មែរ ទៅតាម មហិច្ឆិតារបស់គេ។ បន្តិចៗម្តងៗ ប្រវត្តិសាស្ត្រខ្មែរ ដែលយួនសរសេរនេះ នឹងក្លាយ ជាប្រវត្តិសាស្ត្រ ជាវិទ្យាសាស្ត្រ សំរាប់ខ្មែរ ដូចជាប្រវត្តិសាស្ត្រ ដែលសរសេរដោយដោយបារាំងសែស នោះឯង ព្រោះនៅស្រុកខ្មែរ គ្មាន អ្នកប្រវត្តិសាស្ត្រពិត ជាអ្នកផលិតប្រវត្តិសាស្ត្រ ប្រកបដោយគុណភាព ដែលនាំឲ អំណាច របស់អ្នកដឹកនាំ គេបន្តតួនាទីគេជា អ្នកផលិត ប្រវត្តិសាស្ត្រ។ ហើយអំណាចនេះទៀត សព្វថ្ងៃ នៅក្នុងកណ្តាប់ដៃ របស់អ្នកដឹកនាំយួន រួមនឹង ចំនួនជាតិសាសន៍យួន មករស់នៅស្រុកខ្មែរ មានចំនួនស្មើរស្មើនឹង ជាតិសាសន៍ខ្មែរទៅហើយ ដែលជា **ជោគ** មួយ សំរាប់ ផ្សាយវប្បធម៌ របស់គេ យ៉ាងងាយស្រួលបំផុត ដែលនៅក្នុងនោះសោធ មានប្រវត្តិសាស្ត្រខ្មែរថ្មីមួយ ដែលមានព្រលឹងខ្មែរជាព្រលឹងយួន។ ការនេះ ជាការពិតមួយដែលខ្មែរយើង កំពុងទទួលរងគ្រោះ ឥតអាចខ្មែរណាប្រកែកបាន។ ទស្សនៈនេះ មិនមែនជាទស្សនៈ ជាតិសាសន៍និយមនោះឡើយ ឬ អ្នកជ្រុលនិយម នោះដែរ តែជាប្រតិកម្ម ជាធម្មតារបស់ខ្មែរអ្នកស្រឡាញ់ជាតិ នៅចំពោះមុខ គ្រោះថ្នាក់ជាតិ តែប៉ុណ្ណោះ។ តែប្រតិកម្មគ្មានសកម្មភាព គឺគ្រាន់តែជា **បច្ឆាទុក្ខ**[31] (contrition) ដែលខ្មែរយើងតែងតែមានតែប៉ុណ្ណោះ។

ប្រវត្តិសាស្ត្រ នៅស្រុកខ្មែរ មានពិត ហើយ មានលក្ខណៈដូចជាមាំមួនណាស់ តែជាប្រវត្តិសាស្ត្រសំរាប់ បំរើប្រយោជន៍ អ្នកដឹកនាំតែប៉ុណ្ណោះ ព្រោះជាប្រវត្តិសាស្ត្រ មានប្រភព ចេញពីអំណាចអ្នកដឹកនាំ ដែលយើងអាចប្រដូចទៅនឹង សាធារណឃោសនា (publicité) របស់អ្នកដឹកនាំជាតិ

[30] ជតានិយម=Fatalisme។
[31] បច្ឆាទុក្ខ=ទុក្ខស្តាយក្រោយដោយបានធ្វើខុស។

ដើម្បី ស្វែងរក ប្រយោជន៍អំណាច ដើម្បីពង្រឹងអំណាច តែបើខ្មែរយើង អាន ដោយមានការពិចារណា យើងអាចឃើញមាន ចំណុចខ្មៅច្រើនណាស់ ដែលត្រូវការ មានអ្នកប្រវត្តិសាស្ត្រ ឬ អ្នកស្រឡាញ់ប្រវត្តិសាស្ត្រ លើកយកវា មកបំភ្លឺ រក ភាពវិជ្ជមាន និង អវិជ្ជមាន សំរាប់ទុកជូនសាធារណជន យកវាមកពិចារណា។ **ការត្រិះរិះជាឯក**[32] របស់ប្រវត្តិសាស្ត្រវិទូបរទេសក្តិ របស់អ្នកដឹកនាំ ដែលវង្វែងជាតិក្តី សុទ្ធជាផ្លូវមរណៈ សំរាប់ជាតិសាសន៍ខ្មែរ ដូច្នេះខ្មែរត្រូវមានការណើយកិច្ច មានគំនិតថ្មី ដើម្បីឆ្លុះមើលឡើងវិញ នូវប្រវត្តិសាស្ត្រជាតិ របស់ខ្លួន ដូច្នេះ ខ្មែរត្រូវការ **ធ្វើបដិវត្តន៍គំនិត** ដែលជាឧបករណ៍ សំរាប់កសាងលទ្ធិប្រជាធិបតេយ្យសេរី។ ហើយកុំចេះតែនាំគ្នាខឹងនឹងយួន ដោយមិនយក គុណសម្បត្តិ និង គុណវិបត្តិ ខ្លួន មកពិចារណា រក ដោតដើម្បី តតាំង នឹងគេ តាមរបៀប ប្រាកដនិយមមួយ ដែលខ្លួនអាចធ្វើបាន៕

**- ចប់ -**

ថ្ងៃទី២៨ តុលា ឆ្នាំ ២០១៤

[32] ការត្រិះរិះជាឯក=La pensée unique។